# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៩៧...អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ-បក ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៦ ស្តីពីការប្រែក្លាយពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ទៅជាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៦១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីការតែងតាំង សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ជាសាកលវិទ្យាធិការ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ។
- បានឃើញព្រះសង្ឃប្រកាសលេខ ០០១/០៦ ម.ស.រធត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកំណត់បែងចែកភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបង្កើត " **អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា** " ទទួលបន្ទុកគ្រប់គ្រងលើពុទ្ធិកបឋមសិក្សា រហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា ទូទាំងប្រទេស

**មាត្រា ២ :** អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- គ្រប់គ្រងដឹកនាំនិងរៀបចំកម្មវិធីសិក្សាឱ្យប្រព្រឹត្តទៅឱ្យបានរីកចំរើនល្អប្រសើរ ស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡា
- លើកគម្រោងផ្តល់យោបល់រៀបចំកម្មវិធីសិក្សា ក្នុងផ្នែកចំណេះវិជ្ជាវិស័យព្រះពុទ្ធសាសនា ធម៌វិន័យ បាលី សំស្ក្រឹត
- ពិនិត្យលើកគម្រោង និងសម្របសម្រួលរៀបចំការផ្សព្វផ្សាយកម្មវិធីសិក្សា ឱ្យស្របតាមការវិវត្តន៍នៃនយោបាយរបស់រាជរដ្ឋាភិបាល
- កំណត់ប្រតិទិនច្បាស់លាស់ សម្រាប់ចុះធ្វើការត្រួតពិនិត្យ នៅតាមសាលាពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សាទូទាំងប្រទេស ដោយផ្តោតយកចិត្តទុកដាក់គុណភាពសិក្សា នៅថ្នាក់ពុទ្ធិកបឋមសិក្សាសាលាធម្មវិន័យគ្រប់ថ្នាក់
- លើកគម្រោង និងពិនិត្យពិភាក្សា ជ្រើសរើសលើវិញ្ញាសាសម្រាប់ប្រឡង នៃកម្រិតសិក្សានីមួយៗ ./.

- ពិនិត្យពិភាក្សាលើកគម្រោងជ្រើសរើសគ្រូសម្រាប់បំរើគ្រប់កម្រិតសិក្សា ដោយផ្តល់អាទិភាពគ្រូ នៅពុទ្ធិកសិក្សាក្នុងភេទជាព្រះសង្ឃ ឬ គ្រហស្ថ ដើម្បីបំរើសំណូមពរ នៃគុណភាពសិក្សានៅថ្នាក់មូលដ្ឋាន
- ពិនិត្យពិភាក្សាផ្តល់យោបល់ លើសំណើសុំបង្កើតពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា ទូទាំងប្រទេស មុននឹងដាក់ឆ្លង ក្រសួងធម្មការ និងសាសនា
- ធ្វើការទំនាក់ទំនងទូលាយជាមួយបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនា ថេរវាទ ដែលមានអង្គការពុទ្ធិកសិក្សា ដើម្បីដកស្រង់បទពិសោធន៍ តាមរយៈការធ្វើទស្សនកិច្ចសិក្សានៃគណៈគ្រប់គ្រងនិងសមណនិស្សិតតាមកម្មវិធីជាក់ស្តែង

**មាត្រា ៣** : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយគណៈគ្រប់គ្រងមួយដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-សម្តេចព្រះមហាសុមេធាធិបតី | **នន្ទ ង៉ែត** | អគ្គាធិការ |
| ២-សម្តេចព្រះធម្មលិខិត | **លាស់ ឡាយ** | អគ្គាធិការរង |
| ៣-សម្តេចព្រះឧត្តមមុនី | **ហេង លាងហោ** | អគ្គាធិការរង |
| ៤-សម្តេចព្រះវនរ័ត | **ណយ ច្រឹក** | អគ្គាធិការរង |
| ៥-សម្តេចព្រះពោធិវង្ស | **អ៊ំ លឹមហេង** | អគ្គាធិការរង |
| ៦-សម្តេចព្រះឧត្តមវង្សា | **មួង រ៉ា** | អគ្គាធិការរង |
| ៧-ព្រះឃោសធម្ម | **សោវ៉ី ចំនួនជុល្ល** | អគ្គាធិការរង និងជាលេខាធិការ |
| ៨-ព្រះសទ្ធម្មកោសល | **ជា សំអាង** | អគ្គាធិការរង |

**មាត្រា ៤** : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **មិន ឃិន** ជំនួសមុខឱ្យក្រសួងធម្មការ និងសាសនា ដើម្បីសហការ និងដឹកនាំអគ្គាធិការដ្ឋាន ពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥** : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំលេខាធិការដ្ឋានមួយដឹកនាំដោយព្រះឃោសធម្ម **សោវ៉ី ចំនួនជុល្ល** និងមានសមាជិកមួយចំនួន ជាជំនួយការ

**មាត្រា ៦** : គណៈគ្រប់គ្រងនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ប្រើប្រាស់ត្រាមួយដោយឡែក សំរាប់ដំណើរការងាររបស់ខ្លួន ។

**មាត្រា ៧** : គណៈគ្រប់គ្រងនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ធ្វើការងារប្រចាំថ្ងៃ តាមបទបញ្ជាផ្ទៃក្នុងមួយដែលបានកំណត់ដោយឡែក ។

**មាត្រា ៨** : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដំណើរការងារដោយប្រើប្រាស់ថវិកាក្រសួងធម្មការ និងសាសនា និងអនុវត្តតាមគោលការណ៍កំណត់នៃប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ដែលស្ថិតនៅជាចរមាន និងមានសិទ្ធិទទួលយកជំនួយបច្ចេកទេស ឬហិរញ្ញវត្ថុពីអង្គការជាតិ អន្តរជាតិ ក្នុងការទ្រទ្រង់ឱ្យដំណើរការប្រព្រឹត្តទៅរបស់អធិការដ្ឋាន ពុទ្ធិកបឋមសិក្សា រហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សាទូទាំងប្រទេស ។

**មាត្រា ៩** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីរដ្ឋលេខាធិការ ពាក់ព័ន្ធ និង គ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ។

**មាត្រា ១១** : អនុក្រឹត្យនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- ឯកសារ-កាលប្បវត្តិ